រាជរដ្ឋាភិបាលកម្ពុជា

លេខ ១១៣ អនក្រ.បក

# ព្រះរាជាណាចក្រកម្ពុជា

# ជាតិ សាសនា ព្រះមហាក្សត្រ

# អនុក្រឹត្យ

# ស្តីពី

# ប្រាក់ឧបត្ថម្ភចៅក្រម

# រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខនស/រកត/១១៩៨/៧២ចុះថ្ងៃទី៣០ខែវិច្ឆិកាឆ្នាំ១៩៩៨ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រឹត្យលេខនស/រកត/០៦០២/១៥៨ ចុះថ្ងៃទី១៩ ខែមិថុនា ឆ្នាំ២០០២ ស្តីពីការបង្កើតក្រុមប្រឹក្សាកំណែទម្រង់ច្បាប់និងប្រព័ន្ធយុត្តិធម៌

-យោងតាមការចាំបាច់របស់រាជរដ្ឋាភិបាល

-បានការឯកភាពពីគណៈរដ្ឋមន្ត្រី ក្នុងសម័យប្រជុំពេញអង្គនាថ្ងៃទី១៨ ខែតុលា ឆ្នាំ២០០២

## សម្រេច

### មាត្រា ១

អនុក្រឹត្យនេះ មានគោលដៅកំណត់ប្រាក់ឧបត្ថម្ភចៅក្រម បន្ថែមលើប្រាក់បៀវត្សមូលដ្ឋានប្រចាំខែជូនដល់ចៅក្រម និងព្រះរាជអាជ្ញា ដែលកំពុងបំពេញការងារ អមសាលាជម្រះក្តី និងចៅក្រមដែលកំពុងបំពេញការងារនៅលេខាធិការដ្ឋាន ឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម ក្រសួងយុត្តិធម៌ និងស្ថាប័នរដ្ឋផ្សេងៗទៀត ។

ប្រាក់ឧបត្ថម្ភចៅក្រមនេះ ត្រូវបើកផ្តល់ជូនចាប់ពីខែមករា ឆ្នាំ២០០៣ ។

### មាត្រា ២

ប្រាក់ឧបត្ថម្ភចៅក្រម និង ព្រះរាជអាជ្ញាប្រចាំខែត្រូវកំណត់ដូចខាងក្រោមៈ

-ប្រធានតុលាការកំពូល និងអគ្គព្រះរាជអាជ្ញាអមតុលាការកំពូលចំនួន ២,៥០០ ០០០ រៀល( ពីរលានប្រាំរយពាន់រៀល)

-ប្រធានសាលាឧទ្ធរណ៍ អគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍ អនុប្រធានតុលាការកំពូល និងអគ្គព្រះរាជអាជ្ញារងអមតុលាការកំពូល ចំនួន ២,២០០ ០០០ រៀល( ពីរលានពីររយពាន់រៀល)

-អនុប្រធានសាលាឧទ្ធរណ៍អគ្គព្រះរាជអាជ្ញារងអមសាលាឧទ្ធរណ៍ ចំនួន២,០០០ ០០០រៀល( ពីរលានរៀល)

-ប្រធានតុលាការខេត្ត-ក្រុង ព្រះរាជអាជ្ញាអមតុលាការខេត្ត-ក្រុង ចៅក្រមតុលាការកំពូល ព្រះរាជអាជ្ញាអមតុលាការកំពូល ចៅក្រមសាលាឧទ្ធរណ៍ ព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍ ចៅក្រមបំពេញការងារនៅលេខាធិការដ្ឋាន

ឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម ក្រសួងយុត្តិធម៌ និងស្ថាប័នរដ្ឋផ្សេងៗទៀត ចំនួន១,៧០០ ០០០ រៀល(មួយលានប្រាំពីររយពាន់រៀល)

-អនុប្រធានតុលាការនិងព្រះរាជអាជ្ញារងអមតុលាការខេត្ត-ក្រុងចំនួន១៥០០០០០រៀល (មួយលានប្រាំរយពាន់រៀល)

-ចៅក្រមតុលាការខេត្ត-ក្រុង ចំនួន ១,៣០០ ០០០ រៀល(មួយលានបីរយពាន់រៀល)

-ចៅក្រម ព្រះរាជអាជ្ញា និងព្រះរាជអាជ្ញារងកម្មសិក្សា ត្រូវទទួលបានប្រាក់ឧបត្ថម្ភចៅក្រមចំនួន៥០០ ០០០ រៀល(ប្រាំរយពាន់រៀល)

**មាត្រា ៣**

ចៅក្រមដែលកាន់មុខតំណែងច្រើន ត្រូវបានអនុញ្ញាតអោយជ្រើសរើសយកប្រាក់ឧបត្ថម្ភចៅក្រមតែមួយប៉ុណ្ណោះ ។

**មាត្រា ៤**

បទប្បញ្ញត្តិទាំងឡាយណា ដែលផ្ទុយនឹងអនុក្រឹត្យនេះត្រូវទុកជាភាករណ៍។

**មាត្រា ៥**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ សហប្រធានក្រុមប្រឹក្សាកំណែទម្រង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌ រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ រដ្ឋលេខាធិការនៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួងស្ថាប័ន ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះតាមភារកិច្ចរៀងៗខ្លួនចាប់ពីថ្ងៃចុះហត្ថលេខារតទៅ ។

ធ្វើនៅភ្នំពេញ ថ្ងៃទី១៣ ខែវិច្ឆិកា ឆ្នាំ២០០២

**នាយករដ្ឋមន្ត្រី**

**ហ៊ុន សែន**

**<u>កន្លែងទទួល</u>**

-ក្រសួងព្រះបរមរាជវាំង
-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-លេខាធិការដ្ឋានឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម
-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
-អគ្គលេខាធិការរាជរដ្ឋាភិបាល
-ដូចមាត្រា ៥
-ឯកសារ -កាលប្បវត្តិ